**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន**
**អគ្គលេខាធិការដ្ឋាន**
លេខ: ០៧៦ រ.ប.ក/អ.ជ.ប.គ.ញ

ថ្ងៃពុធ ៤រោច ខែជេស្ឋ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
រាជធានីភ្នំពេញ, ថ្ងៃទី ១០ ខែមិថុនា ឆ្នាំ២០២០

# របាយការណ៍
# ស្ដីពី
# លទ្ធផលការងារត្រួតពិនិត្យគ្រឿងញៀន ខែឧសភា និងលើកទិសដៅការងារខែមិថុនាឆ្នាំ២០២០

(ថ្ងៃទី០១ ដល់ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២០)

ខែឧសភានេះ ទន្ទឹមនឹងការយកចិត្តទុកដាក់អនុវត្តទិសដៅការងារដែលបានដាក់ចេញ កាលពីខែមេសា ឆ្នាំ២០២០ និងផែនការយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់លើកទី៥ អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ក្រសួង-ស្ថាប័នពាក់ព័ន្ធ អាជ្ញាធរដែនដី កងកម្លាំងប្រដាប់អាវុធគ្រប់លំដាប់ថ្នាក់ ក៏ដូចជាវិស័យឯកជន វិស័យសាសនា បានបន្តយកចិត្តទុកដាក់អនុវត្តសកម្មភាពបង្ការ ទប់ស្កាត់ និងបង្ក្រាបបទល្មើសគ្រឿងញៀន ដើម្បីរួមចំណែកថែរក្សានូវសន្តិសុខ និងសណ្ដាប់ធ្នាប់សាធារណៈក្នុងសង្គមជាតិ និងក្នុងស្ថានភាពកម្ពុជាកំពុងមមាញឹកប្រយុទ្ធជំងឺរាលត្បាតកូវីដ-១៩ នៅទូទាំងប្រទេស ដោយទទួលបាននូវលទ្ធផលគួរកត់សម្គាល់។ ជាក់ស្ដែង សភាពការណ៍ សកម្មភាព និងលទ្ធផលការងារដែលសម្រេចបាន និងកំពុងអនុវត្តបន្ត មានដូចខាងក្រោម៖

## I. សភាពការណ៍គ្រឿងញៀន

តាមរយៈកិច្ចប្រតិបត្តិការរបស់កម្លាំងអនុវត្តច្បាប់ ក្នុងខែឧសភានេះ សកម្មភាពចរាចរ ជួញដូរគ្រឿងញៀនខុសច្បាប់នៅតែបន្តកើតមានឡើងនៅក្នុងភូមិសាស្ត្ររាជធានី-ខេត្ត ក្នុងនោះបទល្មើសជួញដូរគ្រឿងញៀនទ្រង់ទ្រាយធំ មានដូចជា ៖ កម្លាំងអធិការដ្ឋានក្រុងបាត់ដំបង បង្ក្រាបករណីរក្សាទុក ដឹកជញ្ជូន ជួញដូរគ្រឿងញៀនខុសច្បាប់ ១ករណី នៅចំណុចក្រុមទី៦ ស្ថិតក្នុងភូមិវត្តគរ សង្កាត់វត្តគរ ក្រុងបាត់ដំបង ឃាត់ខ្លួនជនសង្ស័យចំនួន ១នាក់ ភេទប្រុស ជាជនជាតិខ្មែរ ចាប់យកវត្ថុតាងគ្រឿងញៀនប្រភេទមេតំហ្វេតាមីន(ICE) និងកេតាមីន (ketamine) បានជាង ១គីឡូក្រាម។ ដោយឡែកកម្លាំងមន្ទីរប្រឆាំងគ្រឿងញៀន បានសហការជាមួយកម្លាំងស្នងការដ្ឋាននគរបាលខេត្តកំពង់ស្ពឺ បង្ក្រាបករណីរក្សាទុក ដឹកជញ្ជូន ជួញដូរគ្រឿងញៀនខុសច្បាប់ ១ករណី នៅចំណុចផ្លូវជាតិលេខ៤ ក្នុងភូមិចំបក់ ឃុំវល្លិស ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ ឃាត់ខ្លួនជនសង្ស័យចំនួន ២នាក់ ភេទប្រុស ជាជនជាតិខ្មែរ ចាប់យកវត្ថុតាងគ្រឿងញៀនប្រភេទមេតំហ្វេតាមីន(ICE) បានជាង ៤គីឡូក្រាម។ នៅក្នុងភូមិសាស្ត្ររាជធានីភ្នំពេញ កម្លាំងមន្ទីរប្រឆាំងគ្រឿងញៀន បង្ក្រាបករណីជួញដូរគ្រឿងញៀនខុសច្បាប់ ២ករណីធំៗ ឃាត់ខ្លួនជនសង្ស័យចំនួន ៤នាក់ ភេទប្រុស ក្នុងនោះជនជាតិរុស្ស៊ី ១នាក់ ភេទប្រុស និងជនជាតិតៃវ៉ាន់ ១នាក់ ភេទប្រុស ចាប់យកវត្ថុតាងគ្រឿងញៀនប្រភេទមេតំហ្វេតាមីន(ICE) អ៊ិចស្តាស៊ី (MDMA) កេតាមីន (ketamine) ហេរ៉ូអ៊ីន (Heroin) និងនីមេតាហ្សេប៉ាម (Nimetazepam) បានជាង



អគ្គលេខាធិការដ្ឋាន នៃ អ.ជ.ប.គ.ញ មានទីតាំងនៅក្នុងបរិវេណក្រសួងមហាផ្ទៃ, Phone, Fax: (855) 23 721 648, Fax: (855) 23 727 529 P.O.Box: 151
E-mail: info@nacd.gov.kh Website : www.nacd.gov.kh

៣គីឡូក្រាម។ ទន្ទឹមនេះ ការអនុវត្តវិធានការអប់រំផ្សព្វផ្សាយអំពីបញ្ហាគ្រឿងញៀន ក៏បានធ្វើសកម្មភាពយ៉ាងផុលផុស ដោយគ្របដណ្តប់លើអ្នកទទួលសារអប់រំប្រមាណជាង **១សែន ១ម៉ឺន**នាក់។ ការអនុវត្តវិធានការព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន តាមរយៈការព្យាបាលផ្អែកលើសហគមន៍ក្នុងប្រព័ន្ធសុខាភិបាលមូលដ្ឋាន យើងគ្រប់គ្រងអ្នកប្រើប្រាស់គ្រឿងញៀនចំនួន **១២៦នាក់**។ ព្រមទាំងបានអនុវត្តវិធានការរដ្ឋបាល និងវិធានការច្បាប់ នៅតាមសណ្ឋាគារ ផ្ទះសំណាក់ ផ្ទះជួល ភោជនីយដ្ឋាន ខារ៉ាអូខេ ។ល។ ការពង្រឹង និងពង្រីកកិច្ចសហប្រតិបត្តិការអន្តរជាតិជាមួយប្រទេសជាប់ព្រំដែន ប្រទេសក្នុងតំបន់ និងដៃគូអភិវឌ្ឍន៍ តាមរយៈការផ្លាស់ប្តូរព័ត៌មាន និងចែករំលែកបទពិសោធន៍ឱ្យគ្នាទៅវិញទៅមកតាមប្រព័ន្ធព័ត៌មាន online។

## I. ការដឹកនាំរបស់ស្ថាប័នកំពូលថ្នាក់ជាតិ

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ក្នុងនាមរាជរដ្ឋាភិបាលកម្ពុជា នៅក្នុងខែឧសភានេះ បានបន្តយកចិត្តទុកដាក់លើការងារប្រយុទ្ធប្រឆាំងគ្រឿងញៀន ដោយក្នុងនោះបានបញ្ជ្រាបខ្លឹមសារអប់រំអំពីគ្រោះថ្នាក់នៃគ្រឿងញៀននៅក្នុងវេទិកានានារបស់សម្តេច។

**សម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុន សែន ប្រធានកាកបាទក្រហមកម្ពុជា** ក្នុងខែឧសភានេះ បានបន្តអំពាវនាវដល់គ្រប់ស្រទាប់មហាជន សមត្ថកិច្ចអនុវត្តច្បាប់ ឲ្យខិតខំប្រើប្រាស់វិធានការជំនាញក្នុងការលុបបំបាត់ការជួញដូរ និងប្រើប្រាស់គ្រឿងញៀន ដើម្បីចូលរួមអនុវត្តគោលនយោបាយភូមិ ឃុំ មានសុវត្ថិភាពរបស់រាជរដ្ឋាភិបាល។

**សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ** ក្នុងខែឧសភានេះ បានបន្តផ្តល់អនុសាសន៍ដឹកនាំឲ្យពង្រឹងការអនុវត្តគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព គោលនយោបាយភូមិ-ឃុំ/សង្កាត់ ស គ្មានគ្រឿងញៀន បទបញ្ជាលេខ ០១ ស្តីពីការពង្រឹងវិធានការប្រយុទ្ធប្រឆាំងគ្រឿងញៀន និងផែនការយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់របស់រាជរដ្ឋាភិបាល។ ពង្រឹងការអនុវត្តវិធានការរដ្ឋបាល និងចាត់វិធានការបង្ក្រាបនៅតាមក្លឹបកម្សាន្ត និងទីតាំងសប្បាយដ្ឋាន ដែលពាក់ព័ន្ធនឹងគ្រឿងញៀន។ បន្តស្រាវជ្រាវ បង្ក្រាបករណីផលិតកែច្នៃគ្រឿងញៀន និងករណីដាំដុះដំណាំកញ្ឆា។ ជាមួយគ្នានេះ ក៏បានធ្វើការអំពាវនាវឲ្យគ្រប់មជ្ឈដ្ឋានសង្គម និងកំលាំងអនុវត្តច្បាប់ទាំងអស់ អនុវត្តនូវទិសស្លោក ៣កុំ ១រាយការណ៍គឺៈ ១-កុំឲ្យពាក់ព័ន្ធ ២-កុំអន្តរាគមន៍ ៣-កុំលើកលែង និងត្រូវរាយការណ៍គ្រប់ករណីបទល្មើសគ្រឿងញៀន។

## II. ការដឹកនាំអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន

ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី **កែ គឹមយ៉ាន** ប្រធាន អ.ជ.ប.គ.ញ. បានបន្តដឹកនាំតាមគោលការណ៍សំខាន់ៗដែលបានដាក់ចេញ នៅក្នុងសន្និបាតបូកសរុបលទ្ធផលការងារត្រួតពិនិត្យគ្រឿងញៀនឆ្នាំ២០១៩ និងលើកទិសដៅការងារឆ្នាំ២០២០ និងកិច្ចប្រជុំបូកសរុបលទ្ធផលអនុវត្តផែនការយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់លើកទី៤ កាលពីថ្ងៃទី១៦ ដល់ ថ្ងៃទី១៧ ខែមីនា ឆ្នាំ២០២០ ក្នុងនោះរួមមាន ៖ ការបង្កើនការអប់រំផ្សព្វផ្សាយបង្ការ ទប់ស្កាត់បញ្ហាគ្រឿងញៀន, ការពង្រឹងវិធានការព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន, ការបង្កើនប្រសិទ្ធភាពនៃការទប់ស្កាត់ការចរាចរគ្រឿងញៀន, ការពង្រឹងយន្តការសេនាធិការប្រយុទ្ធប្រឆាំងគ្រឿងញៀនថ្នាក់រាជធានី-ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់, ការពង្រឹងកិច្ចសហ-ប្រតិបត្តិការអន្តរជាតិ, ការបន្តអនុវត្តឲ្យកាន់តែសកម្មនូវផែនការយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់លើកទី៥។ ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី ប្រធាន អ.ជ.ប.គ.ញ. ក៏បានណែនាំ និងអំពាវនាវឱ្យមន្ត្រីរាជការប្រជាពលរដ្ឋ ចូលរួមបង្ការ ទប់ស្កាត់ការរាតត្បាតនៃវីរុសកូវីដ-១៩(COVID-19)នៅប្រទេសកម្ពុជា។

ក្រៅពីការផ្តល់នូវអនុសាសន៍ខាងលើ ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី បានៈ

- ជួបសំណេះសំណាល និងបានធ្វើការបញ្ជ្រាបខ្លឹមសារអប់រំពីបញ្ហាគ្រឿងញៀន ដល់មន្ត្រីរាជការ កង កម្លាំងប្រដាប់អាវុធ សិស្សានុសិស្ស និងប្រជាពលរដ្ឋ នៅក្រុងសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ បានចំនួន **៥.០០០នាក់**

- អនុញ្ញាតឱ្យ ឯកឧត្តម **កើត រិទ្ធ** រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ និងសហការី បានចូលជួបសំដែងការគួរសម និងពិភាក្សាការងារ ពាក់ព័ន្ធនិងការបើកយុទ្ធនាការដោះស្រាយ ការកកស្ទះសំណុំរឿងនៅតាមសាលាដំបូង និងការចង្អៀតណែនក្នុងមណ្ឌលអប់រំកែប្រែ និងពន្ធនាគារនៅតាមរាជធានី-ខេត្ត នៅទីស្ដីការគណៈរដ្ឋមន្ត្រី។

## III. លទ្ធផលការងារប្រយុទ្ធប្រឆាំងគ្រឿងញៀន

ឆ្លើយតបទៅនឹងទិសដៅការងារដែលបានដាក់ចេញកាលពីខែឧសភាឆ្នាំ២០២០ និងយោងតាមការណែនាំរបស់ **ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី ប្រធាន អ.ជ.ប.គ.ញ.** អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ. ក្រសួង-ស្ថាប័នពាក់ព័ន្ធ និងគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី-ខេត្ត បានបន្តអនុវត្តការងារទទួលបានលទ្ធផលដូចខាងក្រោម៖

### ១. ការអប់រំផ្សព្វផ្សាយ បង្ការ ទប់ស្កាត់ និងបដិសេធគ្រឿងញៀន

បានបង្កើនការអប់រំផ្សព្វផ្សាយទៅលើគោលដៅប្រឈមខ្ពស់យ៉ាងសកម្ម និងផុលផុសថែមទៀត ដូចជា ម្ចាស់ផ្ទះសំណាក់ សណ្ឋាគារ កន្លែងកម្សាន្ត ការដ្ឋានសំណង់ ក្រុមហ៊ុនដឹកជញ្ជូន លំនៅដ្ឋានកម្មករក្រៅប្រព័ន្ធ ។ល។ ដោយចលនាឲ្យមានការចូលរួមពីគ្រប់សមាសភាពសង្គម បញ្ជ្រាបខ្លឹមសារអប់រំពីបញ្ហាគ្រឿងញៀនទៅក្នុងគ្រប់វេទិកា និងព្រឹត្តិការណ៍ផ្សេងៗ ក្នុងភូមិសាស្ត្រនៃដែនសមត្ថកិច្ចរបស់ក្រសួង-ស្ថាប័ន និងរាជធានី-ខេត្ត ដោយទទួលបានលទ្ធផលដូចខាងក្រោម៖

#### ១.១. ការងារអប់រំតាមប្រព័ន្ធផ្សព្វផ្សាយ

- អគ្គលេខាធិការ អ.ជ.ប.គ.ញ. បានផ្ដល់បទសម្ភាសន៍ផ្ទាល់ក្នុងកម្មវិធីព្រឹត្តិការណ៍សំខាន់ៗប្រចាំថ្ងៃរបស់ទូរទស្សន៍ជាតិកម្ពុជា ក្រោមប្រធានបទ សកម្មភាព និងវិធានការបង្ការទប់ស្កាត់ បង្ក្រាបការចរាចរ ចែកចាយ ប្រើប្រាស់គ្រឿងញៀនខុសច្បាប់ ដែលកម្ពុជាកំពុងប្រយុទ្ធប្រឆាំងការរាតត្បាតជាសកលនៃវីរុសកូវីដ-១៩(COVID-19)

- តាមរយៈគេហទំព័ររបស់អគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន (www. nacd.gov.kh) ក្នុងខែឧសភាឆ្នាំ២០២០ មានការចូលអានចំនួន **១៦.៧៥៤ដង**

- អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ. បានផ្សព្វផ្សាយឃ្លីបវីដេអូខ្លីៗ ស្ដីពីបញ្ហាគ្រឿងញៀន និងការគោរពច្បាប់ចរាចរណ៍ផ្លូវគោក តាមបណ្ដាញទំនាក់ទំនងសង្គម Page Facebook របស់អគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន

- អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ. សហការជាមួយស្ថានីយទូរទស្សន៍ វិទ្យុ និងបណ្ដាញសារព័ត៌មានអេឡិចត្រូនិក ដើម្បីធ្វើការអប់រំផ្សព្វផ្សាយ ពីផលប៉ះពាល់ និងគ្រោះថ្នាក់នៃការប្រើប្រាស់គ្រឿងញៀន។

#### ១.២. ការងារអប់រំតាមសហគមន៍

- អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ. ក្រសួង-ស្ថាប័នពាក់ព័ន្ធ និងគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី-ខេត្ត បានធ្វើការអប់រំផ្សព្វផ្សាយពីផលប៉ះពាល់ និងគ្រោះថ្នាក់នៃគ្រឿងញៀន នៅតាមវេទិកាសាធារណៈ តាមសហគ្រាស តាមគ្រឹះស្ថានសិក្សា និងកម្មវិធីនានានៅក្នុងសហគមន៍មួយចំនួន។ល។

- អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ. បានធ្វើសកម្មភាពអប់រំផ្សព្វផ្សាយ ផលប៉ះពាល់នៃការប្រើប្រាស់គ្រឿងញៀន និងបង្ការ ទប់ស្កាត់ការរាតត្បាតនៃវីរុសកូវីដ-១៩(COVID-19) តាមបណ្ដាញទំនាក់ទំនងសង្គម Page Facebook របស់អគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន។

ដោយឡែកគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី-ខេត្ត បានធ្វើការអប់រំផ្សព្វផ្សាយពីបញ្ហាគ្រឿងញៀនបានចំនួន **៥.៦៩១**លើក ដោយគ្របដណ្ដប់លើអ្នកមកទទួលយកសារ **១១០.៤៨៧**នាក់/ស្រី **៥៥.០០០**នាក់ ក្នុងនោះ ៖ តាមគ្រឹះស្ថានសិក្សា **៣**លើក អ្នកចូលរួម **១៥៦**នាក់/ស្រី **៧០**នាក់, តាមវេទិកាសាធារណៈ **៣.៨៨៦**លើក អ្នកចូលរួម **១០៨.១៩៦**នាក់/ស្រី **៥៣.៩០១**នាក់, តាមរយៈវិស័យសាសនា **២៣**លើក អ្នកចូលរួម **១.៤៩១**នាក់/ស្រី **៨៤៩**នាក់, តាមរយៈប្រព័ន្ធផ្សព្វផ្សាយ **១.៦៩៣**លើក និងចុះចែកខិត្តប័ណ្ណ **៧០**លើក ស្មើនឹង **១២.៩២៦**សន្លឹក និងនៅតាមរោងចក្រ សហគ្រាស ពន្ធនាគារ អង្គភាព **១៦**លើក អ្នកចូលរួម **៦៤៤**នាក់/ស្រី **១៨០**នាក់។

- សរុបអ្នកដែលមកទទួលសារអប់រំនៅក្នុងខែឧសភានេះមានប្រមាណ **១សែន ១ម៉ឺននាក់ ស្រី ៥ម៉ឺននាក់**។

- ដោយឡែក ក្រសួងសាធារណការ និងដឹកជញ្ជូន បានបន្តស្នើសុំឲ្យក្រុមហ៊ុនដឹកជញ្ជូនទាំងអស់ ធ្វើការណែនាំដល់អ្នកបើកបរយានយន្តកុំឲ្យប្រើប្រាស់គ្រឿងញៀន ឬគ្រឿងស្រវឹង និងស្នើឲ្យបិទខិត្តប័ណ្ណផ្សព្វផ្សាយយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់ នៅតាមយានយន្ត និងជលយាន។

## ២. ការកាត់បន្ថយគ្រោះថ្នាក់បណ្ដាលមកពីការប្រើប្រាស់គ្រឿងញៀន ការព្យាបាល ស្តារនីតិសម្បទា បណ្តុះបណ្តាលវិជ្ជាជីវៈ បំណិនជីវិត ការធ្វើសមាហរណកម្ម និងការចាកចេញពីគ្រឿងញៀន

ជាមួយនឹងការណែនាំឲ្យពង្រឹង សមត្ថភាព គុណភាព និងប្រសិទ្ធភាព នៃការព្យាបាល ស្តារនីតិសម្បទានិង សមាហរណកម្ម ដូចជា ៖ ការជំរុញឱ្យបានសកម្មនូវដំណើរការព្យាបាលតាមសហគមន៍, ពង្រឹងសមត្ថភាពមណ្ឌលបណ្ដោះអាសន្នរដ្ឋ និងឯកជន ដោយពង្រឹងផ្នែកវេជ្ជសាស្ត្របណ្ដុះបណ្ដាលវិជ្ជាជីវៈ និងសមាហរណកម្ម កាត់បន្ថយការលាប់ឡើងវិញ, បង្កើតយន្តការជាក់លាក់សម្រាប់ការធ្វើសមាហរណកម្ម និងការថែទាំបន្តនៅតាមឃុំ-សង្កាត់, បង្កើតប្រព័ន្ធគ្រប់គ្រងទិន្នន័យអ្នកញៀនគ្រឿងញៀនឱ្យបានច្បាស់លាស់តាមបច្ចេកវិទ្យាទំនើបនាពេលបច្ចុប្បន្ន និងសហការជាមួយដៃគូពាក់ព័ន្ធដើម្បីស្រាវជ្រាវរកវិធីសាស្ត្រព្យាបាលអ្នកញៀនគ្រឿងញៀនឱ្យកាន់តែល្អប្រសើរឡើង, គាំទ្រក្នុងការបញ្ជូនអ្នកប្រើប្រាស់គ្រឿងញៀនដែលមិនបានទទួលសេវាព្យាបាល ឱ្យទៅទទួលសេវាព្យាបាល ដោយប្រើប្រាស់គ្រប់យន្តការ ទាំងយន្តការអប់រំ លើកទឹកចិត្ត និងយន្តការអនុវត្តច្បាប់ យើងក៏បានបន្តអនុវត្តការងារទទួលបានលទ្ធផលដូចខាងក្រោម៖

### ២.១. ការកាត់បន្ថយគ្រោះថ្នាក់បណ្ដាលមកពីការប្រើប្រាស់គ្រឿងញៀន

- ក្រសួងសុខាភិបាល បន្តផ្តល់សេវាព្យាបាលដោយឱសថជំនួសមេតាដូន ដល់អ្នកញៀនគ្រឿងញៀនប្រភេទអាភៀន(ហេរ៉ូអ៊ីន)នៅខែឧសភានេះ មានអ្នកទៅទទួលសេវាព្យាបាលចំនួន ៧១នាក់ ស្រី ១០នាក់

- បន្តការគាំទ្រចំពោះអង្គការជាដៃគូ ដែលបាននិងកំពុងអនុវត្តកម្មវិធីផ្តល់សេវាម្ជុល-ស៊ីរ៉ាំងចំពោះអ្នកប្រើប្រាស់គ្រឿងញៀនដោយចាក់ ដើម្បីកាត់បន្ថយការឆ្លងមេរោគអេដស៍ និងរោគឆ្លងតាមឈាមផ្សេងៗទៀត។

### ២.២. ការព្យាបាល និងស្តារនីតិសម្បទា

បានបន្តជំរុញឲ្យគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី-ខេត្ត ពង្រឹង និងបង្កើតគណៈកម្មការសម្របសម្រួលសម្រាប់ការព្យាបាលអ្នកញៀនគ្រឿងញៀនដោយផ្អែកលើសហគមន៍ នៅតាមឃុំ-សង្កាត់ ដើម្បីជំរុញ និងគាំទ្រឲ្យអ្នកប្រើប្រាស់ និងអ្នកញៀនគ្រឿងញៀនមានភាពងាយស្រួលទៅទទួលយកសេវាព្យាបាល នៅតាមមណ្ឌលសុខភាព មន្ទីរពេទ្យបង្អែក និងលើកកម្ពស់ការថែទាំបន្តនៅតាមសហគមន៍។

## ៣. ការពង្រឹងប្រសិទ្ធភាពស្ថាប័នអនុវត្តច្បាប់

ទន្ទឹមនឹងការណែនាំឲ្យបង្កើនប្រសិទ្ធភាពនៃការទប់ស្កាត់ និងបង្ក្រាបជាអាទិភាពនូវការហូរចូលគ្រឿងញៀននៅតាមតំបន់ព្រំដែនកម្ពុជា-ឡាវ កម្ពុជា-ថៃ កម្ពុជា-វៀតណាម ព្រលានយន្តហោះ និងបញ្ញើប្រៃសណីយ៍ ដោយផ្តោតទៅលើការពង្រឹងការប្រមូលព័ត៌មានពីគ្រប់ប្រភព សំដៅវែកមុខពួកឧក្រិដ្ឋជនទាំងក្នុងនិងក្រៅប្រទេស ឈានទៅបង្ក្រាបបាននូវបណ្តាញជួញដូរគ្រឿងញៀន ការយកចិត្តទុកដាក់ទៅលើគោលដៅប្រឈមនានា ដូចជា កន្លែងកម្សាន្តស និងតំបន់ស្មុគស្មាញផ្សេងៗ យើងក៏បានបន្តអនុវត្តការងារទទួលបានលទ្ធផលដូចខាងក្រោម៖

### ៣.១. ការពង្រឹងសមត្ថភាពការងារអនុវត្តច្បាប់

- អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ. បានបំពេញព័ត៌មានគ្រឿងញៀនត្រៀមកិច្ចប្រជុំតាមអនឡាញរបស់ស្ថាប័នត្រួតពិនិត្យគ្រឿងញៀន នៃបណ្តាលប្រទេសហត្ថលេខីទាំង៦ ក្នុងមហាអនុតំបន់ទន្លេមេគង្គ ដែលរៀបចំដោយការិយាល័យអង្គការសហប្រជាជាតិទទួលបន្ទុកគ្រឿងញៀន និងឧក្រិដ្ឋកម្ម (UNODC)
- ថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ. បានចូលរួមត្រួតពិនិត្យ និងធ្វើការវិភាគលើសារធាតុចាប់យកក្នុងបទល្មើសគ្រឿងញៀន ដើម្បីធ្វើការដកយកសំណាកដែលសង្ស័យថាជាសារធាតុញៀនយកទៅធ្វើកោសលវិច័យ នៅសាលាដំបូងរាជធានីភ្នំពេញ
- អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ. បានចាត់បញ្ជូនមន្ត្រីទៅចូលរួមកិច្ចប្រជុំ ស្តីពីការបូកសរុបលទ្ធផលនៃការបញ្ចូលទិន្នន័យបទល្មើសគ្រឿងញៀន និងស្នេនខ្មៅដៃជនល្មើស នៅក្នុងប្រព័ន្ធគ្រប់គ្រងបទល្មើសគ្រឿងញៀន (Database System) និងផ្សព្វផ្សាយបន្ថែមមុខងារថ្មីៗ(Update)របស់ប្រព័ន្ធដែលរៀបចំដោយមន្ទីរប្រឆាំងគ្រឿងញៀន នៅសាលប្រជុំមន្ទីរប្រឆាំងគ្រឿងញៀន។

### ៣.២. លទ្ធផលបង្ក្រាបករណីគ្រឿងញៀន

ក្នុងខែឧសភានេះ កិច្ចប្រតិបត្តិការបង្ក្រាបករណីគ្រឿងញៀនរួមមានដូចខាងក្រោម ៖

- **បទល្មើសគ្រឿងញៀនសរុប បង្ក្រាបបាន ៩៣៨ករណី** (ធៀបនឹងខែមេសា/២០២០, មាន **៩១២ករណី**) កើនលើស ២៦ករណី ស្មើនឹង ២,៨៥% ក្នុងនោះ៖
  - ករណីជួញដូរ រក្សាទុក ៦១៦ករណី
  - ករណីប្រើប្រាស់ ៣១៩ករណី
  - ករណីដាំដុះ ០៣ករណី
- **ជនសង្ស័យសរុប ឃាត់ខ្លួនមាន ១.៨៨៦នាក់ ស្រី ១២៦នាក់** (ធៀបខែមេសា/២០២០, មាន **១.៧២៨** នាក់) កើនលើស ១៥៨នាក់ ស្មើនឹង ៩,១៤% ក្នុងនោះ៖

- ជនសង្ស័យក្នុងករណីជួញដូរ រក្សាទុក ១,១៧៥នាក់ (ស្រី ៩៧នាក់)
- ជនសង្ស័យក្នុងករណីប្រើប្រាស់គ្រឿងញៀន ៧១០នាក់ (ស្រី ២៩នាក់)
- ជនសង្ស័យក្នុងករណីដាំដុះ ០១នាក់

ជនសង្ស័យរួមមាន ៖ ជនជាតិខ្មែរ ១.៨៦២នាក់ (ស្រី ១២៣នាក់) និងជនជាតិបរទេស ២៤នាក់ (ស្រី ៣នាក់) ស្មើនឹង ៤ជនជាតិ គឺ ៖ វៀតណាម ១៥នាក់ (ស្រី ៣នាក់), ចិន ៧នាក់, តៃវ៉ាន់ ១នាក់ និង រុស្ស៊ី ១នាក់ បានកសាងសំណុំរឿងបញ្ជូនទៅសាលាដំបូងរាជធានី-ខេត្ត។

– **គ្រឿងញៀនសរុប** ចាប់យកបានចំនួន ១៧គ.ក្រ ២០០.២០ក្រាម (ធៀបនឹងខែមេសា/២០២០, ៩០គ.ក្រ ០៩៨.២៨ក្រាម) ថយចុះ ៧២គ.ក្រ ៨៩៨.០៨ក្រាម ស្មើនឹង ៨០,៩% ក្នុងនោះ៖

- មេតំហ្វេតាមីនក្រាមម្សៅ (ICE) ១២គ.ក្រ ៣១៤.១៣ក្រាម
- មេតំហ្វេតាមីនគ្រាប់(WY) ៩៦.១០ក្រាម
- អ៊ិចស្តាស៊ី(MDMA) ៣៤៥.៥៩ក្រាម
- កេតាមីន ៦៧៦.៤៧ក្រាម
- ហេរ៉ូអ៊ីន **៣**គ.ក្រ ៤៨៧.៩២ក្រាម
- កូកាអ៊ីន ៤.៨១ក្រាម
- Nimetazapam **២៧៥.១៨**ក្រាម

– **កញ្ឆាស្រស់**ចំនួន ១,៤៥២ដើម

– **កញ្ឆាក្រៀម**ចំនួន ១១,១៥៦.៧៨ក្រាម

– **សម្ភារចាប់យក** ក្នុងប្រតិបត្តិការបង្ក្រាបបទល្មើសគ្រឿងញៀន ដែលបានបញ្ជូនទៅសាលាដំបូងរាជធានី-ខេត្ត រួមមាន ៖ រថយន្តចំនួន ១១គ្រឿង, ម៉ូតូចំនួន ២៩៧គ្រឿង, ទូរសព្ទ ៨២៦គ្រឿង, ជញ្ជីង ៤៤ គ្រឿង, ប្រាក់កម្ពុជាចំនួន ១២,៨៦៤,៣០០រៀល, ប្រាក់អាមេរិក ១,៣០០ដុល្លារ ប្រាក់ថៃ ៥,០០០បាត និងប្រាក់វៀតណាម ១០,១៦៩,៥០០ដុង។

**ក្នុងចំនួនករណីគ្រឿងញៀនខាងលើ ៖**

➢ ករណីគ្រឿងញៀនបង្ក្រាបដោយ **សមត្ថកិច្ចនគរបាលចំនួន ៨៤១ករណី** ឃាត់ខ្លួនជនសង្ស័យចំនួន ១.៦២២នាក់ (ស្រី ១០២នាក់)។

➢ ករណីគ្រឿងញៀនបង្ក្រាបដោយ **សមត្ថកិច្ចកងរាជអាវុធហត្ថចំនួន ៩៧ករណី** ឃាត់ខ្លួនជនសង្ស័យចំនួន ២៦៤**នាក់** (ស្រី ២៤នាក់)។

– **ជនសង្ស័យចាប់តាមដីកា** មានចំនួន ៤៤ដីកា ឃាត់ខ្លួនជនសង្ស័យចំនួន ៤២នាក់ (ស្រី ០នាក់)។

### ៣.៣. ការអនុវត្តវិធានការរដ្ឋបាល ៖

អនុវត្តវិធានការរដ្ឋបាលបានចុះធ្វើតេស្តរកសារធាតុញៀនលើក្មេងទំនើង ជនមានតម្រុយប្រើប្រាស់គ្រឿងញៀន និងធ្នាក់ត្រួតពិនិត្យអ្នកបើកបររថយន្តដឹកទំនិញ ដឹកកម្មករ ដឹកអ្នកដំណើរ បុគ្គលិកក្លឹបកម្សាន្ត កាស៊ីណូ សណ្ឋាគារ ខារ៉ាអូខេ សរុបចំនួន ៧៩**លើក** ស្មើនឹង ៤៣៥នាក់/**ស្រី ៤នាក់ រកឃើញអ្នកផ្ទុកសារធាតុញៀន ១៤៩នាក់** ត្រូវបានសមត្ថកិច្ចធ្វើការបញ្ជូនតាមនីតិវិធីច្បាប់ឲ្យទៅទទួលយកសេវាបន្សាប និងព្យាបាល។

### ៣.៤. លទ្ធផលកោសលវិច័យលើសំណាកសង្ស័យជាគ្រឿងញៀន

– សំណាកសង្ស័យជាគ្រឿងញៀន ដែលបានធ្វើកោសលវិច័យក្នុងខែឧសភា ឆ្នាំ២០២០ មានចំនួន **៦៥៧ករណី** ស្មើនឹង **៧១៩សំណាក** ក្នុងនោះ៖

- **សំណាកវិជ្ជមានសារធាតុញៀន** មានចំនួន **៦៩១សំណាក** (៩៦,០៦%) គឺ៖
  - ➢ មេតំហ្វេតាមីនគ្រាប់ (WY) ១៥សំណាក = ២,០៨%
  - ➢ មេតំហ្វេតាមីនក្រាមម្សៅ (ICE) ៦៤៣សំណាក = ៨៩,៤២%
  - ➢ សារជាតុញៀនប្រភេទ (កេតាមីន) ១២សំណាក = ១,៦៦%
  - ➢ សារជាតុញៀនប្រភេទ (អ៊ិចស្តាស៊ី) ១៨សំណាក = ២,៥០%
  - ➢ សារជាតុញៀនប្រភេទ (នីមេតាហ្សេប៉ាម) ២សំណាក = ០,២៧%
  - ➢ សារជាតុញៀនប្រភេទ (ហេរ៉ូអ៊ីន) ១សំណាក = ០,១៣%
- **សំណាកអវិជ្ជមានសារធាតុញៀន = ២៨សំណាក** (៣,៨៩%)។

– ផ្តល់តេស្តរកសារជាតុញៀនឈ្មោះ (ម៉ាគ្វីតេស្ត)ចំនួន ៣០០មីល្លីលីត្រ តេស្តរកសារជាតុញៀនឈ្មោះ(កេតាមីនតេស្ត)ចំនួន ១០តេស្ត និងស្រោមសំបុត្ររក្សាវត្ថុតាងចំនួន ៤០០សន្លឹក ដល់អង្គភាពចំនួន០៥ គឺមន្ទីរប្រឆាំងគ្រឿងញៀន ស្នងការដ្ឋាននគរបាលខេត្តកណ្តាល ស្នងការដ្ឋាននគរបាលខេត្តកំពង់ស្ពឺ ស្នងការដ្ឋាននគរបាលខេត្តត្បូងឃ្មុំ និងស្នងការដ្ឋាននគរបាលខេត្តកំពង់ចាម។

## ៤. ការត្រួតពិនិត្យសារធាតុគីមីផ្សំ

ជាមួយនឹងការណែនាំឱ្យបង្កើនការយកចិត្តទុកដាក់គ្រប់គ្រង ត្រួតពិនិត្យសារជាតុគីមីផ្សំ វត្ថុជាតុដើម ព្រមទាំងសារជាតុផ្សំផ្សេងទៀត ដើម្បីបង្ការ និងទប់ស្កាត់ការលួចបង្វែរពីជំនួញស្របច្បាប់យកទៅផលិតគ្រឿងញៀនខុសច្បាប់ អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ. បានចូលរួមសហការជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ ក្នុងការប្រមូលព័ត៌មាន និងត្រួតពិនិត្យឯកសារការអនុញ្ញាតឲ្យនាំចូលនូវសារជាតុញៀន និងសារជាតុគីមីផ្សំ ដែលបានកំណត់ក្នុងតារាងឧបសម្ព័ន្ធនៃច្បាប់ ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ជាក់ស្តែងក្នុងខែឧសភាឆ្នាំ២០២០ សរុបចំនួន ៥.១៥១.០០២^គ.ក្រ^ ៦៥៣^ក្រាម^ ដែលស្ថិតក្នុង៖

- ➢ តារាងទី៤ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន៖
  - – ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ បានផ្តល់អាជ្ញាប័ណ្ណនាំចូលសារជាតុគីមីផ្សំចំនួន ២៦.០០០^គ.ក្រ^
  - – ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា បានផ្តល់អាជ្ញាប័ណ្ណនាំចូលសារជាតុគីមីផ្សំចំនួន ៥.១២៥.០០០^គ.ក្រ^។
- ➢ តារាងទី២ ទី៣ និងទី៤ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន៖
  - – ក្រសួងសុខាភិបាល បានផ្តល់អាជ្ញាប័ណ្ណនាំចូលសារជាតុញៀន ជាឱសថមានផ្ទុកសារជាតុញៀនចំនួន ១^គ.ក្រ^ ៧៥៣^ក្រាម^។
  - – ក្រសួងសុខាភិបាល បានផ្តល់អាជ្ញាប័ណ្ណនាំចូលវត្ថុជាតុដើម ក្នុងតារាងទី៤ ចំនួន ៩០០^ក្រាម^។

## ៥. កិច្ចសហប្រតិបត្តិការអន្តរជាតិជាមួយប្រទេសជាប់ព្រំដែន

បានបង្កើនកិច្ចសហប្រតិបត្តិការអន្តរជាតិជាមួយប្រទេសជាប់ព្រំដែន តាមរយៈការអនុវត្តស្មារតីនៃកិច្ចព្រមព្រៀងទ្វេភាគីជាមួយប្រទេសថៃ ឡាវ និងប្រទេសវៀតណាម រួមមាន៖

**៥.១.** ជាមួយភាគីថៃ ៖ បន្តពង្រឹងយន្តការភូមិ ឃុំ សង្កាត់ ស គ្មានគ្រឿងញៀនរវាងខេត្តព្រះវិហារ ជាមួយខេត្តអូរប៊ុន។

**៥.២.** ជាមួយភាគីឡាវ ៖ បន្តពង្រឹងយន្តការភូមិ ឃុំ សង្កាត់ ស គ្មានគ្រឿងញៀនរវាងខេត្តស្ទឹងត្រែង ជាមួយខេត្តចាំប៉ាសាក់។

**៥.៣.** ជាមួយភាគីវៀតណាម ៖ រៀបចំឯកសារនានាសម្រាប់ការបង្កើតការិយាល័យទំនាក់ទំនងព្រំដែន(BLO)អូរយ៉ាដាវ ក្នុងខេត្តរតនគិរី ជាមួយនិងខេត្តយ៉ាឡាយ។

## ៦. កិច្ចសហប្រតិបត្តិការអន្តរជាតិជាមួយប្រទេសក្នុងតំបន់ និងដៃគូអភិវឌ្ឍន៍នានា

បានបន្តពង្រឹង និងពង្រីកកិច្ចសហប្រតិបត្តិការអន្តរជាតិជាមួយប្រទេសនានាក្នុងសកលលោក ក្នុងតំបន់ និងដៃគូអភិវឌ្ឍន៍នានា តាមគ្រប់យន្តការ ទ្វេភាគី ត្រីភាគី ពហុភាគី ដើម្បីទប់ស្កាត់ការចរាចរ និងការប្រើប្រាស់គ្រឿងញៀន ក៏ដូចជាការបន្តកិច្ចសហការជាមួយអង្គការដៃគូជាតិ និងអន្តរជាតិ ដើម្បីគាំទ្រការងារប្រយុទ្ធប្រឆាំងគ្រឿងញៀននៅកម្ពុជា យើងបានបន្តអនុវត្តការងារទទួលបានលទ្ធផលដូចខាងក្រោម៖

**៦.១.** អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ. បានរៀបចំកិច្ចប្រជុំត្រៀមសម្រាប់កិច្ចប្រជុំមន្ត្រីសម្របសម្រួលប្រទេសហត្ថលេខី នៃអនុស្សរណៈយោគយល់គ្នា(MOU) ស្តីពីការត្រួតពិនិត្យគ្រឿងញៀនក្នុងមហាអនុតំបន់ទន្លេមេគង្គ នៅសាលប្រជុំអគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ។

**៦.២.** អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ. បានទទួលវេនម្ចាស់ផ្ទះរៀបចំកិច្ចប្រជុំតាមប្រព័ន្ធអនឡាញ បណ្តាប្រទេសហត្ថលេខីនៃអនុស្សរណៈយោគយល់គ្នា(MOU) ឆ្នាំ១៩៩៣ ស្តីពីការត្រួតពិនិត្យគ្រឿងញៀនក្នុងមហាអនុតំបន់ទន្លេមេគង្គ ដែលរៀបចំដោយអគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ. និងការិយាល័យអង្គការសហប្រជាជាតិទទួលបន្ទុកគ្រឿងញៀន និងឧក្រិដ្ឋកម្ម (UNODC) នៅសាលប្រជុំអគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ។

## ៧. ការពង្រឹងយន្តការត្រួតពិនិត្យគ្រឿងញៀននៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ

ជាមួយនឹងការណែនាំឲ្យពង្រឹងយន្តការសេនាធិការ ដើម្បីអនុវត្តការដឹកនាំពហុវិស័យក្នុងការប្រយុទ្ធប្រឆាំងគ្រឿងញៀននៅថ្នាក់រាជធានី-ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ និងដើម្បីជំរុញប្រសិទ្ធភាពការងារប្រយុទ្ធប្រឆាំងគ្រឿងញៀនឱ្យទទួលបានលទ្ធផលល្អប្រសើរ និងមាននិរន្តរភាពទាំងការងារតាមដានបូកសរុបរបាយការណ៍ និងវាយតម្លៃសភាពការណ៍គ្រឿងញៀន ក៏ដូចជាការបន្តអនុវត្តគោលនយោបាយលើកទឹកចិត្តដល់អង្គភាព បុគ្គលមានស្នាដៃពិតប្រាកដក្នុងការងារប្រយុទ្ធប្រឆាំងគ្រឿងញៀន នៅតាមក្រសួង-ស្ថាប័ន និងអង្គភាពពាក់ព័ន្ធរួមទាំងវិស័យឯកជនផងនោះ យើងបានបន្តអនុវត្តការងារទទួលបានលទ្ធផលដូចខាងក្រោម៖

**៧.១.** អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ. បានចាត់បញ្ជូនមន្ត្រីចូលរួមកិច្ចប្រជុំគណៈកម្មការដឹកនាំគម្រោង និងក្រុមការងារបច្ចេកទេស ដើម្បីពិនិត្យវឌ្ឍនភាព ការអភិវឌ្ឍសម្ភារឧបទ្ទេស ក្រោមអធិបតីភាពលោកជំទាវ **សឿ សុជាតា** អនុរដ្ឋលេខាធិការ ក្រសួងអប់រំ យុវជន និងកីឡា នៅសាលប្រជុំពហុបំណងនាយកដ្ឋានសុខភាពសិក្សា ជាន់ទី៣ អគាររដ្ឋបាលថ្មីចៅពញាហុក។

**៧.២.** ថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ. បានចូលរួមក្នុងកម្មវិធីផ្សព្វផ្សាយរបាយការណ៍ជាតិការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សឆ្នាំ២០១៩ និងទិសដៅការងារឆ្នាំ២០២០ របស់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស(គ.ជ.ប.ជ) ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ទីស្តីការក្រសួងមហាផ្ទៃ។

**៧.៣.** ថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ. បានចូលរួមក្នុងពិធីប្រកាសសម្រួលភារកិច្ច ផ្ទេរភារកិច្ច តែងតាំងមុខតំណែង និងតម្លើងឋានន្តរស័ក្តិ ជូននាយនគរបាលក្រសួងមហាផ្ទៃ ក្រោមអធិបតីភាព ឯកឧត្តម នាយឧត្តមសេនីយ៍ **មៀច សុផាន់ណា** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ នៅទីស្តីការក្រសួងមហាផ្ទៃ។

**៧.៤.** អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ. បាននឹងកំពុងបន្តនីតិវិធីរៀបចំសេចក្តីព្រាងគោលនយោបាយ ជាតិសម្រាប់ការបង្កើតភូមិ-ឃុំ/សង្កាត់ ស គ្មានគ្រឿងញៀន។

## IV. ទិសដៅត្រួតពិនិត្យគ្រឿងញៀន ខែមិថុនាឆ្នាំ២០២០

ដើម្បីអនុវត្តបន្តឲ្យមានប្រសិទ្ធភាពលើការងារត្រួតពិនិត្យគ្រឿងញៀន អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ. បានដាក់ចេញនូវទិសដៅការងារសម្រាប់**ខែមិថុនាឆ្នាំ២០២០** ដូចខាងក្រោម៖

### ១. ការអប់រំ ផ្សព្វផ្សាយ បង្ការ ទប់ស្កាត់ និងបដិសេធគ្រឿងញៀន

**១.១.** អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ. បន្តកិច្ចសហការជាមួយក្រសួង-ស្ថាប័ន សមាជិកអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន និងគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី-ខេត្ត ដើម្បីផ្សព្វផ្សាយច្បាប់ ស្តីពីការត្រួតពិនិត្យគ្រឿងញៀន, សភាពការណ៍គ្រឿងញៀន, ចំណេះដឹងជាមូលដ្ឋានអំពីផលប៉ះពាល់ និងគ្រោះថ្នាក់នៃគ្រឿងញៀន នៅតាមតំបន់គោលដៅសំខាន់ៗដែលងាយរងគ្រោះដោយសារគ្រឿងញៀន។

**១.២.** អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ. បន្តរៀបចំវេទិកាតុមូលដើម្បីអនុវត្តផែនការយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់លើកទី៥។

**១.៣.** អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ. បន្តរៀបចំវេទិកាជួបជាមួយវិស័យឯកជន ដើម្បីអនុវត្តផែនការយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់លើកទី៥។

**១.៤.** អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ. បន្តសហការជាមួយស្ថានីយទូរទស្សន៍ វិទ្យុ និងបណ្តាញសារព័ត៌មានអេឡិចត្រូនិកដើម្បីធ្វើការផ្សព្វផ្សាយពីការងារដែលទាក់ទងនឹងបញ្ហាគ្រឿងញៀន។

**១.៥.** អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ. បន្តចលនាឲ្យមានការចូលរួមពីអង្គការមិនមែនរដ្ឋាភិបាល និងវិស័យឯកជន ក្នុងការងារអប់រំផ្សព្វផ្សាយ ពីផលប៉ះពាល់ និងគ្រោះថ្នាក់នៃគ្រឿងញៀន។

**១.៦.** អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ. បន្តបោះពុម្ពខិត្តប័ណ្ណអប់រំពីផលប៉ះពាល់ និងគ្រោះថ្នាក់នៃគ្រឿងញៀន សម្រាប់អប់រំផ្សព្វផ្សាយទៅលើក្រុមគោលដៅដែលងាយរងគ្រោះដោយសារការប្រើប្រាស់គ្រឿងញៀន។

**១.៧.** អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ. បន្តជំរុញ និងសម្របសម្រួលជាមួយក្រុមហ៊ុន និងវិស័យឯកជន ដើម្បីធ្វើសកម្មភាពផ្សព្វផ្សាយអប់រំពីគ្រោះថ្នាក់នៃគ្រឿងញៀន នៅក្នុងកម្មវិធីផ្សេងៗ និងទិវាបុណ្យជាតិសំខាន់ៗ។

**១.៨.** អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ. ត្រៀមរៀបចំផែនការបណ្តុះបណ្តាលគ្រូបង្គោលនៅតាមបណ្តាក្រសួង-ស្ថាប័ន អង្គភាព ជាពិសេសតាមបណ្តាខេត្ត។

**១.៩.** អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ. បន្តទំនាក់ទំនងជាមួយសាលារាជធានីភ្នំពេញសម្របសម្រួលដាក់តាំងរូបភាព សារអប់រំពីបញ្ហាគ្រឿងញៀននៅតាមបញ្ជរចំណតរថយន្តក្រុង។

## ២. ការកាត់បន្ថយគ្រោះថ្នាក់បណ្តាលមកពីការប្រើប្រាស់គ្រឿងញៀន ការព្យាបាល ស្តារនីតិសម្បទា បណ្តុះបណ្តាលវិជ្ជាជីវៈ បំណិនជីវិត ការធ្វើសមាហរណកម្ម និងការចាកចេញពីគ្រឿងញៀន

**២.១.** អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ. បន្តជំរុញសកម្មភាពផ្សព្វផ្សាយឲ្យកាន់តែសកម្ម ដើម្បីឲ្យអ្នករងគ្រោះដោយសារគ្រឿងញៀន បានដឹងភ្ញាក់រលឹក និងស្ម័គ្រចិត្តទៅទទួលយកសេវាព្យាបាលនៅតាមមន្ទីរពេទ្យបង្អែក ឬមណ្ឌលសុខភាព។

**២.២.** អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ. ជំរុញ និងពង្រឹងសមត្ថភាព គុណភាព នៃយន្តការគ្រប់គ្រងមណ្ឌលបណ្តោះអាសន្ន សម្រាប់អប់រំ បន្សាប ព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន។

**២.៣.** អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ. បន្តសហការរៀបចំ និងពង្រឹងមន្ទីរពេទ្យបង្អែក និងមណ្ឌលសុខភាពឱ្យមានលទ្ធភាព និងសមត្ថភាពអាចទទួលព្យាបាលអ្នកញៀនគ្រឿងញៀនដោយផ្អែកលើសហគមន៍ បណ្តារាជធានី-ខេត្ត ក៏ត្រូវរៀបចំយន្តការគាំទ្រចំពោះដំណើរការព្យាបាលនេះផងដែរ។

**២.៤.** អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ. បន្តពង្រឹងគណៈកម្មការសម្របសម្រួលដល់ការព្យាបាលអ្នកញៀនគ្រឿងញៀន ក្នុងសហគមន៍ នៅតាមឃុំ-សង្កាត់ ដើម្បីជំរុញ និងគាំទ្រឲ្យអ្នកប្រើប្រាស់ និងអ្នកញៀនគ្រឿងញៀនមានភាពងាយស្រួលទៅទទួលយកសេវាព្យាបាលនៅតាមមណ្ឌលសុខភាព-មន្ទីរពេទ្យបង្អែក និងលើកកម្ពស់ការថែទាំបន្តនៅតាមសហគមន៍។

**២.៥.** អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ. បន្តសម្របសម្រួល និងជំរុញការដាក់ឱ្យដំណើរការមជ្ឈមណ្ឌលជាតិផ្តល់សេវាព្យាបាលដោយស្ម័គ្រចិត្ត និងផ្អែកលើ សហគមន៍ដល់អ្នកញៀនគ្រឿងញៀន នៅភូមិឫស្សី២ ឃុំកែវផុស ស្រុកស្ទឹងហាវ ខេត្តព្រះសីហនុ។

**២.៦.** អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ. បន្តជំរុញការរៀបចំសេវាព្យាបាល និងស្តារនីតិសម្បទាដល់អ្នកញៀនគ្រឿងញៀន ដែលជាទណ្ឌិតនៅតាមមណ្ឌលអប់រំកែប្រែ និងពន្ធនាគារ។

**២.៧.** អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ. បន្តចលនា និងផ្តល់ការសម្របសម្រួលឲ្យមានការចូលរួមពីវិស័យឯកជន លើការងារព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន។

**២.៨.** អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ. ត្រៀមចុះត្រួតពិនិត្យមណ្ឌលព្យាបាល ស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន របស់រដ្ឋ និងឯកជន។

**២.៩.** អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ. បន្តការងារចុះMOUជាមួយអង្គការ Aids Care China លើការងារព្យាបាលអ្នកញៀនគ្រឿងញៀនតាមសហគមន៍។

**២.១០.** អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ. បន្តជំរុញលេខាធិការដ្ឋានគណៈកម្មាធិការទទួលបន្ទុកការងារព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន ដាក់របៀបវារៈកិច្ចប្រជុំឆ្លងការងារកំណត់លក្ខខណ្ឌសម្រាប់ការព្យាបាលអ្នកញៀនតាមសហគមន៍ មណ្ឌលជាតិ និងមណ្ឌលបណ្តោះអាសន្ន។

**២.១១.** អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ. បន្តសម្របសម្រួលឯកសារព្រាងអនុស្សរណៈយោគយល់គ្នារវាងអគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន និងសាលាភូមិន្ទរដ្ឋបាល។

**២.១២.** អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ. បន្តសម្របសម្រួលបញ្ជូនឯកសារព្រាងទៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាសម្របសម្រួលលើកញ្ចប់ថវិកាសម្រាប់មជ្ឈមណ្ឌលជាតិផ្តល់សេវាព្យាបាលដោយស្ម័គ្រចិត្ត និងផ្អែកលើសហគមន៍ដល់អ្នកញៀនគ្រឿងញៀន។

## ៣. ការពង្រឹងប្រសិទ្ធភាពស្ថាប័នអនុវត្តច្បាប់

**៣.១.** អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ. បន្តកិច្ចសហការជាមួយ ការិយាល័យអង្គការសហប្រជាជាតិទទួលបន្ទុកគ្រឿងញៀន និងឧក្រិដ្ឋកម្ម(UNODC) និងក្រុមប្រឹក្សាត្រួតពិនិត្យគ្រឿងញៀនថៃ (ONCB) ក្នុងការរៀបចំការិយាល័យទំនាក់ទំនងព្រំដែន (**BLO**) ថ្មី កម្ពុជា-វៀតណាម ចំនួន ១កន្លែង នៅច្រកទ្វារព្រំដែនអន្តរជាតិអូយ៉ាដាវ (ខេត្តរតនគិរី) ការរៀបចំការិយាល័យទំនាក់ទំនងព្រំដែន (**BLO**)ថ្មី កម្ពុជា-ថៃ ចំនួន ១កន្លែង នៅច្រកទ្វារព្រំដែនអន្តរជាតិជប់គគីរ(ខេត្តឧត្តរមានជ័យ) និងការរៀបចំការិយាល័យទំនាក់ទំនងព្រំដែន (**BLO**)ថ្មី កម្ពុជា-ឡាវ ចំនួន ១កន្លែង នៅច្រកទ្វារព្រំដែនអន្តរជាតិព្រះរំកិល (ស្ទឹងត្រែង) ឲ្យបានចប់ជាស្ថាពរ។

**៣.២.** អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ. ត្រៀមបើកវគ្គបណ្តុះបណ្តាលស្តីពីការពង្រឹងសមត្ថភាពមន្ត្រី អនុវត្តច្បាប់គ្រឿងញៀនតាមមេរៀនក្នុងប្រព័ន្ធកុំព្យូទ័រ(CBT) និងតាមប្រព័ន្ធអេឡិចត្រូនិក (e-Learning) នៅអគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ. និងតាមបណ្តាខេត្ត។

**៣.៣.** អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ. ត្រៀមជួបពិភាក្សាការងារជាមួយសមាជិកដែលពាក់ព័ន្ធ អំពីការអនុវត្តគម្រោង PATROL នៅតាមច្រកទ្វារព្រំដែនអន្តរជាតិនីមួយៗ។

**៣.៤.** អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ. បន្តជំរុញការពង្រឹងសមត្ថភាពមន្ត្រីអនុវត្តច្បាប់ លើការងារត្រួតពិនិត្យគ្រឿងញៀននៅប្រទេសកម្ពុជា សម្រាប់ខែឧសភាឆ្នាំ២០២០។

**៣.៥.** អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ. បន្តរៀបចំវគ្គបណ្តុះបណ្តាលច្បាប់ ស្តីពីការត្រួតពិនិត្យគ្រឿងញៀនដល់មេឃុំ ចៅសង្កាត់ នាយប៉ុស្តិ៍នគរបាល និងមន្ត្រីទទួលបន្ទុកការងារគ្រឿងញៀននៅតាមមូលដ្ឋាន។

## ៤. ការត្រួតពិនិត្យសារធាតុគីមីផ្សំ

**៤.១.** អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ. បន្តពង្រឹងកិច្ចសហការជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ ក្នុងការគ្រប់គ្រងត្រួតពិនិត្យសារជាតុគីមីផ្សំ វត្ថុធាតុដើម ព្រមទាំងសារជាតុផ្សំផ្សេងទៀត ដើម្បីបង្ការ ទប់ស្កាត់ការលួចបង្វែរពីជំនួញស្របច្បាប់យកទៅផលិតគ្រឿងញៀនខុសច្បាប់។

**៤.២.** អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ. បន្តសហការជាមួយក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ រៀបចំវគ្គបណ្តុះបណ្តាលដល់មន្ត្រី បុគ្គលិក ក្រុមហ៊ុនឧស្សាហកម្មគីមី រោងចក្រសហគ្រាស ឲ្យមានការយល់ដឹងពីសារជាតុគីមីផ្សំដែលអាចបង្វែរយកទៅផលិតជាគ្រឿងញៀនខុសច្បាប់។

**៤.៣.** អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ. បន្តរៀបចំវគ្គបណ្តុះបណ្តាលដល់មន្ត្រីអនុវត្តច្បាប់នៅតាមបណ្តារាជធានី-ខេត្ត ស្តីពីការស៊ើបអង្កេតការចរាចរសារជាតុគីមីផ្សំ និងមន្ទីរពិសោធន៍គ្រឿងញៀនលួចលាក់។

**៤.៤.** អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ. បន្តកិច្ចសហការប្រមូលព័ត៌មានពាក់ព័ន្ធ នឹងការប្រើប្រាស់សារជាតុញៀនថ្មី ដែលមានឥទ្ធិពលលើប្រព័ន្ធសរសៃប្រសាទ។

**៤.៥.** អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ. បន្តសម្របសម្រួលជាប្រចាំជាមួយក្រសួងសុខាភិបាល ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ និងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ក្នុងការផ្តល់របាយការណ៍ ស្តីពីការគ្រប់គ្រង ត្រួតពិនិត្យលើការស្នើសុំការអនុញ្ញាតនាំចូលនូវសារជាតុគីមីផ្សំ។

## ៥. កិច្ចសហប្រតិបត្តិការអន្តរជាតិជាមួយប្រទេសជាប់ព្រំដែន

អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.៣. បន្តសម្របសម្រួលជាមួយបណ្តាប្រទេសផ្តល់ជំនួយ ដើម្បីស្វែងរកប្រភពថវិកាសម្រាប់ការបង្កើតការិយាល័យទំនាក់ទំនងព្រំដែន (BLO) អូរយ៉ាដាវ ក្នុងខេត្តរតនគិរីជាមួយនិងខេត្តយ៉ាឡាយ ប្រទេសវៀតណាម និងការពង្រឹងភូមិ ឃុំ/សង្កាត់ ស គ្មានគ្រឿងញៀនតាមបណ្តាយព្រំដែន។

## ៦. កិច្ចសហប្រតិបត្តិការអន្តរជាតិជាមួយប្រទេសក្នុងតំបន់ និងដៃគូអភិវឌ្ឍនានា

**៦.១.** អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.៣. បន្តជំរុញកិច្ចសហប្រតិបត្តិការទ្វេភាគី និងពហុភាគីជាមួយបណ្តាប្រទេសក្នុងតំបន់និងអង្គការដៃគូ ដើម្បីអនុវត្តគោលនយោបាយរបស់រាជរដ្ឋាភិបាល ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

**៦.២.** អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.៣. បន្តកិច្ចសហប្រតិបត្តិការទ្វេភាគីកម្ពុជា-ចិន ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

## ៧. ការពង្រឹងយន្តការត្រួតពិនិត្យគ្រឿងញៀននៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ

**៧.១.** អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.៣. បន្តនីតិវិធីពិនិត្យខ្លឹមសារនៃសេចក្តីព្រាងច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការត្រួតពិនិត្យគ្រឿងញៀន និងច្បាប់ស្តីពីការចាត់ចែងជាបណ្តោះអាសន្ននូវវត្ថុចាប់យកជាមួយក្រសួងយុត្តិធម៌។

**៧.២.** អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.៣. ត្រៀមផ្សព្វផ្សាយផែនការជាតិ៥ឆ្នាំ(២០១៩-២០២៣) ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

**៧.៣.** អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.៣. បន្តរៀបចំសេចក្តីព្រាងគោលនយោបាយជាតិសម្រាប់ការបង្កើត ភូមិ-ឃុំ/សង្កាត់ ស គ្មានគ្រឿងញៀន។

**៧.៤.** អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.៣. បន្តសម្របសម្រួលសហការជាមួយក្រសួងមហាផ្ទៃរៀបចំបញ្ចូលសមាសភាពគណៈកម្មការភូមិ ឃុំ/សង្កាត់ ស គ្មានគ្រឿងញៀន និងគណៈកម្មការសម្របសម្រួលការព្យាបាលអ្នកញៀនគ្រឿងញៀនដោយផ្អែកលើសហគមន៍ នៅតាមឃុំ សង្កាត់ ចូលក្នុងគណៈកម្មការភូមិ ឃុំ មានសុវត្ថិភាពគ្រប់លំដាប់ថ្នាក់។

**៧.៥.** អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.៣. ត្រៀមរៀបចំប្រារព្ធពិធីទិវាអន្តរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០២០។

**អគ្គលេខាធិការ**

នាយឧត្តមសេនីយ៍ **មាស_វីរិទ្ធ**

**ចម្លងជូន**
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
- ឯកឧត្តម ជួន សុវណ្ណ អនុប្រធាន អ.ជ.ប.គ.៣
- ខុទ្ទកាល័យ ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី ប្រធាន អ.ជ.ប.គ.៣
  " ដើម្បីជូនជ្រាប "
- ក្រសួង ស្ថាប័ន សមាជិក អ.ជ.ប.គ.៣
- គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី-ខេត្ត
- នាយកដ្ឋានសរុប ទីស្តីការគណៈរដ្ឋមន្ត្រី
  " ដើម្បីមុខការ "
- ឯកសារ-កាលប្បវត្តិ